# ឧបករណ៍តន្ត្រីបុរាណខ្មែរ
# ចម្លាក់លើជញ្ជាំងប្រាសាទអង្គរ

អត្ថបទនេះ ជាសង្ខេបបទនៃអត្ថបទវែងរបស់ខ្ញុំលើប្រធានបទខាងលើ។ ទី១ កន្លងមក យើងឃើញថា មានតែបរទេសទេដែលបានសរសេរស៊ីជម្រៅទៅលើប្រធានបទពាក់ព័ន្ធនឹងឧបករណ៍តន្ត្រីបុរាណខ្មែរនាសម័យមុនអង្គរនិងអង្គរ។[១] ទី២ អំណះអំណាងនៅលើចំណុចមួយចំនួននៅក្នុងអត្ថបទទាំងនេះ ដូចជាឧបករណ៍ «ចាប៉ី និង រនាត» ជាដើម ជាអំណះអំណាង ជាការបកស្រាយ និងជាសំយោគមតិផ្ទាល់ខ្លួនដោយគ្មានឯកសារជាក់លាក់រឹងមាំមកគាំទ្រ ព្រោះយើងគ្មានឯកសារគ្រប់គ្រាន់។[២] ខ្ញុំចោទជាសំណួរថាតើយើងមានឧបករណ៍ចាប៉ី និង រនាតដែរឬទេនាសម័យនោះ?។ បើមាន ហេតុអ្វីបានជាគេមិនឆ្លាក់ឧបករណ៍ទាំងនោះនៅលើជញ្ជាំងប្រាសាទដូចឧបករណ៍ឯទៀត?។ ឯកសារពាក់ព័ន្ធនឹងឧបករណ៍រនាតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ចង្អុលបង្ហាញថា រនាតមានដើមកំណើតនៅក្រោយសម័យអង្គរ។[៣] ទី៣ សំណេរខ្លះ មានការភាន់ច្រឡំរវាងឧបករណ៍ «គង» ថាជា «រនាត»។[៤] ទី៤ អំណះអំណាង ការបកស្រាយនិងសំយោគមតិទាំងនេះ ជាវិធីសាស្ត្រ «កាត់ក្បាលតម្រូវមួក» មិនមែន «កាត់មួកតម្រូវក្បាល» នោះទេ។ ទី៥ ទោះជាយ៉ាងនេះក៏ដោយ ខ្ញុំយល់ឃើញថា វាជាជំហាននិងចំណុចចាប់ផ្ដើមល្អ ដែលទាំងបរទេស ជាពិសេសទាំងយើងជាខ្មែរ ត្រូវបន្តធ្វើការសិក្សាស្រាវជ្រាវស៊ីជម្រៅបន្ថែមទៀត ទៅលើប្រធានបទនេះ ដើម្បីឈានទៅដល់គោលដៅនិងសម្រេចបាននូវភាពសុក្រឹត។

នៅក្នុងអត្ថបទខ្លីនេះ ខ្ញុំធ្វើការសិក្សានិងពិនិត្យទៅលើរូបចម្លាក់និងសិលាចារឹកដែលបង្ហាញនិងរៀបរាប់អំពីឧបករណ៍តន្ត្រីបុរាណខ្មែរនាសម័យមុនអង្គរនិងអង្គរ។ ខ្ញុំប្រើពាក្យ «អង្គរ» ដោយសំដៅទៅលើប្រាសាទនានានៅក្នុងតំបន់អង្គរ ពោលគឺមិនត្រឹមតែប្រាសាទ

---

[១] Arsenio Nicolas (2021); Patrick Kersalé (2021); Martin Knust (2010)

[២] Arsenio Nicolas 2021: 6, 13; Kersalé 2021: 6, 23, 38, 39

[៣] Yupho (1960); Kubik (1962, 1963); Jones (1963); Johnston (1972, 1973); Morton (1976); Miller and Chonpairot (1981); Sam (2002)

[៤] Arsenio Nicolas 2021: 13

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

អង្គរវត្តតែមួយប៉ុណ្ណោះទេ។ ក្នុងបណ្ដាប្រាសាទបុរាណខ្មែរនានា មានប្រាសាទ សំបូរព្រៃគុក ភ្នំជីសូរ អង្គរវត្ត បាយ័ន បាពួន លានជល់ដំរី ធម្មានន្ទ បន្ទាយឆ្មារ បន្ទាយសម្រែ លលៃ មេបុណ្យខាងកើត ព្រះពិធុ និងប្រាសាទតូចៗមួយចំនួន ដែលមានចម្លាក់រូបឧបករណ៍តន្ត្រីបុរាណខ្មែរ ឆ្លាក់ជាប់ជាតឹកតាងនៃភាពលូតលាស់រុងរឿងនៃវប្បធម៌អរិយធម៌ខ្មែរ។ ឯប្រាសាទខ្លះ ក៏មានរៀបរាប់នៅក្នុងសិលាចារឹកទៀតផង។ ឧបករណ៍តន្ត្រីទាំងនេះរួមមាន ម៉ិម ពិណ ខ្សែ១ ទ្រស័ង្ខ ស្នែង ត្រែ ស្រឡៃ ខ្លុយ ពាទ្យ គងញី (គងដោះ) គងឈ្មោល (គងរាប) គងតូច គងធំ ឈឹង ឆាប ដួង កណ្ដឹង សម្ភោរ ស្គរយោល ស្គរឈ្នះ ស្គរជ័យ និងស្គរធំ។

ខ្ញុំសូមធ្វើការកត់សម្គាល់ថា ឧបករណ៍តន្ត្រីបុរាណខ្មែរខ្លះដែលបានរៀបរាប់ខាងលើនេះ មានការវិវត្តនិងការអភិវឌ្ឍច្នៃប្រឌិតបន្ថែមដែលខ្មែរយើងប្រើប្រាស់នៅក្នុងវង់តន្ត្រីផ្សេងៗនាពេលបច្ចុប្បន្ន ដូចជាវង់តន្ត្រីពិណពាទ្យនិងមហោរីជាដើម។ ដោយឡែកឧបករណ៍ម៉ិម ដែលឆ្លាក់នៅលើជញ្ជាំងប្រាសាទបាយ័ន នៅមានប្រើក្នុងចំណោមជនជាតិភាគតិចនាភូមិភាគឦសាននៃប្រទេសកម្ពុជា មានគ្រឹង ទំពួន ប្រាយ ព្រៅ ពួង ជាដើម។ ចំណែកឯឧបករណ៍ពិណ ក៏ខ្មែរយើងបានយកចិត្តទុកដាក់ធ្វើឱ្យរស់ឡើងវិញ ក្រោយពីអវត្តមានអស់រយៈពេលរាប់រយឆ្នាំកន្លងមក៕

 

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង













អត្ថបទដោយ៖ បណ្ឌិត សំ សំអាង







អត្ថបទដោយ៖ បណ្ឌិត សំ សំអាង











# ឯកសារយោង


Johnston, Thomas Frederick. (19672). *The Music of the ShanganaTsonga*. Ph.D. Dissertation, Univwersity of the Witwatersrand, South Africa.

________. (October 31-November 3, 1973). *Tsonga Aesthetics and Song Text Subject Matter*. Paper presented at the Sixteenth Annual Meeting of the African Studies Association, Syracuse, New York.

Jones, A. M. (1963). "Experiment with a Xylophone Key," *African Music*, *3*(2), 6-10.

Kersalé, Patrick. (August 25, 2021). *Reviving the Musical Instruments of Khmer Empire*.

Knust, Martin. (2010). "Urged to Interdiscilinary Approaches: The Iconography of Music on the Reliefs of Angkor Wat," *Music in Art*, *35*(1-2).

Kubik, Gerhard. (1962). "The Endora Xylophone of Bukonjo," *African Music*, *3*(1), 43-48.

________. (1963). "Discovery of a Trough Xylophone in Northern Mozambique," *African Music*, *3*(2), 11-14.

Miller, Terry, and Jarernchai, Chonpairot. (1981). "The Ranat and Bong-lang: The Question of Origin of the Thai Xylophones," *Ethnomusicology*, (69), 145-163.

Morton, David. (1976). *The Traditional Music of Thailand*. Berkeley: University of California Press.

Nicolas, Arsenio. (2021). *Musical Instruments on the 16$^{th}$ Century Bas-Reliefs in the North Gallery-East Wing of Angkor Wat: Dating and Significance*. The SEAMEO SPAFA International Conference on Southeast Asian Archeology and Fine Arts.

Sam, Sam-Ang. (2002). *Musical Instruments of Cambodia*. Osaka: National Museum of Ethnology.

Yupho, Dhanit. (1960). *Thai Musical Instruments*. Bangkok: Siva Phorn.


អត្ថបទដោយ៖ បណ្ឌិត សំ សំអាង